រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

060KH01A-01

ព្រះអំណោយទានខាងព្រលឹងវិញ្ញាណ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៦០

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ប្រទានព្រះហឫទ័យប្រណី
សន្តោសរបស់ព្រះអង្គដល់ក្រុមជំនុំ ដើម្បីធ្វើអោយការប្រើព្រះ-
អំណោយទានផ្សេងៗក្នុងក្រុមជំនុំ ស៊ីសង្វាក់គ្នា និង ឯកភាពគ្នា
ក្នុងសេចក្តីស្រឡាញ់ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។

**ព្រះអំណោយទានខាងព្រលឹងវិញ្ញាណ ជាព្រះហឫទ័យ
ប្រណីសន្តោសពិសេស ដែលគ្រីស្តជនគ្រប់រូបទទួលបាន
ពីព្រះជាម្ចាស់ ដើម្បីបំពេញកិច្ចការថ្វាយព្រះគ្រីស្ត ។
អស្ចារ្យណាស់ ដែលព្រះជាម្ចាស់ផ្តាល់ធ្វើកិច្ចការរបស់
ព្រះអង្គតាមរយៈយើង ! សូមថ្វាយសិរីរុងរឿងដល់
ព្រះនាមព្រះអង្គ ! ។**

ព្រះអំណោយទានសំរាប់ធ្វើកិច្ចការបំរើ

*«បងប្អូនម្នាក់ៗបានទទួលព្រះអំណោយទានផ្សេងៗពីគ្នាហើយ
ដូច្នេះ ចូរយកព្រះអំណោយទានទាំងនេះទៅបំរើអ្នកឯទៀតៗ
អោយសមនឹងតួនាទីរបស់បងប្អូន ជាអ្នកចាត់ចែងដ៏ល្អដែល
ចែកព្រះអំណោយទានគ្រប់បែបយ៉ាងរបស់ព្រះជាម្ចាស់* » ។

(១ ពេត្រុស ៤:១០)

- តើអ្នកនឹងលើកទឹកចិត្តសមាជិកថ្មីរបស់ក្រុមជំនុំដោយរបៀប
ណា ដើម្បីឱ្យពួកគេចាប់ផ្តើមធ្វើការងារថ្វាយព្រះគ្រីស្ត ? ។

- តើអ្នកនឹងធ្វើដូចម្តេច ដើម្បីអោយសមាជិករបស់ក្រុមជំនុំ
ប្រើប្រាស់ព្រះអំណោយទាន ឬ បំពេញកិច្ចការបំរើ ដែល
ទាក់ទងនឹងអំណោយទានអោយបានសមរម្យ និង មាន
សណ្តាប់ធ្នាប់ក្នុងក្រុមជំនុំអ្នក ? ។

- តើអ្នកនឹងជួយសមាជិក អោយអាចចូលរួមធ្វើមុខងារបំរើក្នុងការថ្វាយបង្គំ និង បំពេញមុខងារបំរើផ្សេងទៀត ដោយរបៀបណា ? ។

_____

_____

_____

- តើអ្នកនឹងជួយសមាជិក អោយអាចប្រើប្រាស់ព្រះអំណោយទានរបស់ពួកគេក្នុងពេលប្រជុំ ឬ ក្នុងសហគមន៍ ដោយរបៀបណា ? ។

_____

_____

_____

- តើអ្នកនឹងធ្វើដូចម្តេច ដើម្បីអោយអ្នកជឿទាំងអស់បំពេញកិច្ចការបំរើរបស់ពួកគេរៀងៗខ្លួន រៀងរាល់សប្តាហ៍ គឺមិនមែនគ្រាន់តែនៅពេលថ្វាយបង្គំប៉ុណ្ណោះទេ ? ។

_____

_____

_____

លោកពេត្រុសប្រាប់អោយយើងប្រព្រឹត្តខ្លួន ជាអ្នកបំរើរបស់ព្រះ-ជាម្ចាស់ ដែលចេះយកព្រះអំណោយទានដែលព្រះជាម្ចាស់ប្រទានអោយយើង ទៅបំរើអ្នកដទៃ ។

តើយើងទទួលបានព្រះអំណោយទាន ដើម្បីធ្វើអ្វី ?

☐ ដើម្បីកសាងខ្លួនយើងផ្ទាល់អោយចំរើនឡើង ។

☐ ដើម្បីបំរើអ្នកដទៃ ។

យោងទៅតាម ១ ពេត្រុស ៤:១០ តើអ្នកណាត្រូវយកព្រះអំណោយទានទៅបំរើអ្នកដទៃ ?

☐ មានតែអ្នកដឹកនាំក្រុមជំនុំប៉ុណ្ណោះ ដែលត្រូវធ្វើ ។

☐ អ្នកជឿទាំងអស់ត្រូវធ្វើ ។

អ្នកជឿលើព្រះគ្រីស្តគ្រប់រូបបំរើព្រះអម្ចាស់ ដោយបំរើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ តាមរយៈព្រះអំណោយទាន ដែលពួកគេបានទទួល ។

ព្រះអំណោយទានសំរាប់កសាងអោយចំរើនឡើង

«ព្រះអង្គបានប្រណីសន្តោសយើងម្នាក់ៗ តាមកិរិតព្រះអំណោយទានដែលព្រះគ្រីស្តប្រទានមកយើង » ។ ហេតុនេះហើយបានជាមានថ្លែងទុកថា÷ *«ព្រះអង្គបានយាងឡើងទៅស្ថានខ្ពស់ ព្រះអង្គបាននាំពួកជាប់ជាឈ្លើយទៅជាមួយ ហើយព្រះអង្គប្រទានព្រះអំណោយទានផ្សេងៗដល់មនុស្សលោក »* ។

«ពាក្យថា "យាងឡើងទៅ" នោះបានសេចក្តីថា ដូចម្តេច ? គឺបានសេចក្តីថា ព្រះអង្គបានយាងចុះមកផែនដីជ័ទាបនេះ ជាមុនសិន ។ ព្រះអង្គដែលបានយាងចុះមកនោះ ជាព្រះអង្គដែលបានយាងឡើងទៅទីជ័ខ្ពស់បំផុតនៃស្ថានបរមសុខ ដើម្បីបំពេញអ្វីៗទាំងអស់ » ។

«គឺព្រះអង្គហើយ ដែលបានប្រទានឱ្យអ្នកខ្លះមានមុខងារជាគ្រីស្តទូត អោយអ្នកខ្លះថ្លែងព្រះបន្ទូល អ្នកខ្លះផ្សាយដំណឹងល្អ អ្នកខ្លះជាអ្នកគង្វាល និង អ្នកខ្លះទៀតជាអ្នកបង្រៀន ដើម្បីរៀបចំប្រជាជនជ័វិសុទ្ធ អោយបំពេញមុខងារបំរើ និង កសាងព្រះកាយរបស់ព្រះគ្រីស្តឡើង » ។

(អេភេសូ ៤:៧-១២)

កិច្ចការដែលត្រូវអនុវត្ត

សូមអធិស្ឋាន ហើយឆ្លើយសំណួរខាងក្រោមនេះ និង អនុវត្តផែនការរបស់អ្នក ។

- តើអ្នកនឹងធ្វើដូចម្តេចដើម្បីជួយអ្នកជឿម្នាក់ៗ នៅក្នុងក្រុមជំនុំអ្នក អោយអាចដឹងពីព្រះអំណោយទានរបស់ខ្លួន និង ធ្វើអោយព្រះអំណោយទានរបស់ខ្លួនរីកចំរើនឡើង ? ។

- សូមសរសេរគំរោងសេចក្តីអធិប្បាយមួយ អំពីព្រះអំណោយទាន ។

© Project WorldReach © SEAN

៥- តើព្រះជាម្ចាស់ប្រទានអោយអ្នកជឿគ្រប់គ្នា មានអំណោយទានដូចគ្នាទាំងអស់ឬទេ ? ។_____

៦- តើយើងអាចមើលស្គាល់ព្យាការីក្លែងក្លាយ ដោយរបៀបណា ? ។

_____

_____

_____

_____

៧- តើលោកភីលីពមានព្រះអំណោយទានអ្វីខ្លះ ? ។

_____

_____

_____

៨- ព្រះអំណោយទានមានប្រយោជន៍ តែនៅពេលដែលយើងប្រើប្រាស់ដោយ :

☐ សេចក្តីស្រឡាញ់ ។

☐ និយាយពាក្យសំដីដែលមានខ្លឹមសារ ។

យោងទៅតាមអត្ថបទគម្ពីរនេះ តើអ្នកណាប្រទានព្រះអំណោយទាន ? ។_____

តើអ្នកណាទទួលព្រះអំណោយទាន ? ។ _____

ដើម្បីអ្វី ? (សូមអានឃ្លាចុងក្រោយរបស់អត្ថបទគម្ពីរនោះ) ។

_____

ព្រះអម្ចាស់ប្រទានព្រះអំណោយទានដល់អ្នកជឿគ្រប់រូប ។ ព្រះអង្គប្រទានឱ្យពួកអ្នកដឹកនាំនូវព្រះអំណោយទានដែលចាំបាច់ សំរាប់បណ្តុះបណ្តាលគ្រីស្តជនគ្រប់រូប ឱ្យអាចបំពេញមុខងារបំរើ ដើម្បីកសាងក្រុមជំនុំអោយរីកចំរើនឡើង ។

១ កូរិនថូស ១២:៤-៩ បង្ហាញថា ព្រះវិញ្ញាណតែមួយទេ ដែលប្រទានអោយអ្នកជឿមានព្រះអំណោយទានផ្សេងៗ ដើម្បីអោយអ្នកជឿបំរើព្រះអម្ចាស់តែមួយព្រះអង្គ ដោយប្រើព្រះអំណោយទានផ្សេងៗនេះ ។

យោងទៅតាម អេភេសូ ៤:៧-១២ ព្រះអម្ចាស់ប្រទានព្រះ-អំណោយទានសំរាប់បំពេញកិច្ចការបំរើជា :

- គ្រីស្តទូត (ចែកចាយដំណឹងល្អ ក្នុងកន្លែងដែលមិនទាន់មានអ្នកណាទៅផ្សាយដំណឹងល្អនៅឡើយ) ។
- អ្នកថ្លែងព្រះបន្ទូល (ចែកចាយព្រះបន្ទូលពិសេស ដែលមកពីព្រះជាម្ចាស់) ។
- អ្នកផ្សព្វផ្សាយដំណឹងល្អ (ដឹកនាំមនុស្សអោយជឿលើព្រះ-យេស៊ូ) ។
- គ្រូគង្វាល (ឃ្វាលរាស្ត្ររបស់ព្រះជាម្ចាស់ក្នុងឋានៈជាអ្នកគ្រប់គ្រង) ។
- អ្នកបង្រៀន (បង្រៀនព្រះបន្ទូលព្រះជាម្ចាស់ ប្រកបដោយប្រសិទ្ធិភាព និង ណែនាំពួកអ្នកស្តាប់អោយអនុវត្តព្រះបន្ទូលព្រះអង្គ ក្នុងជីវិតរបស់ពួកគេ) ។

បទគម្ពីរនេះបង្ហាញថា ព្រះជាម្ចាស់មិនមែនចង់អោយពួកអ្នកដឹកនាំបំពេញកិច្ចការបំរើ ដោយខ្លួនឯងនោះទេ ប៉ុន្តែ ពួកគេត្រូវបណ្តុះបណ្តាលប្រជារាស្ត្ររបស់ព្រះជាម្ចាស់ អោយអាចបំពេញមុខងារបំរើ ដើម្បីអោយក្រុមជំនុំរបស់ព្រះគ្រីស្តរីកចំរើនឡើង ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- តើព្រះអំណោយទានខាងព្រលឹងវិញ្ញាណសំរាប់ធ្វើអ្វី ? ។

_____

_____

២- ហេតុអ្វីបានជាក្រុមជំនុំទ្រឹងមិនទៅមុខ បើសិនជាគ្រូគង្វាលទទួចចង់ធ្វើកិច្ចការគ្រប់យ៉ាង ដោយខ្លួនឯង ? ។

_____

_____

៣- អ្នកណាប្រទានព្រះអំណោយទានខាងព្រលឹងវិញ្ញាណ ? ។

_____

៤- សូមសរសេរវគ្គគម្ពីរបី ឬ បួនដែលបង្រៀនអំពីអំណោយទាន :

_____

_____

_____

_____

© Project WorldReach © SEAN

ព្រះអំណោយទាន (ឬ ការប៉ិនប្រសប់) ខាងសិល្បៈ និង ការឆ្នៃប្រឌិត ។

សេរីភាព ៣៥:៣០-៣៦:១ ។

តើអ្នកណាអាចរៀបចំគំរោងអំពីទីកន្លែង និង របៀបដាក់ប័ណ្ណធំៗសំរាប់ផ្សាយដំណឹងល្អ គ្រឿងសង្ហារឹម ឬ គ្រឿងតុបតែងលំអនៅកន្លែងថ្វាយបង្គំ ។ល។ ?

សំដែងជាឆាកល្ខោន ឬ រឿងខ្លីៗ ដើម្បីផ្សាយដំណឹងល្អ និងបង្រៀន ?

ព្រះជាម្ចាស់អាចប្រទានព្រះអំណោយទានផ្សេងៗច្រើនទៀត ។ ព្រះអំណោយទានខ្លះ អាចសំរាប់តែកាលៈទេសៈពិសេសមួយ ។ ព្រះអំណោយទានខ្លះទៀត សំរាប់ប្រើប្រាស់រយៈពេលយូរ ឬ ពេញមួយជីវិត ។ តើព្រះជាម្ចាស់មានប្រទានអំណោយទានអ្វីផ្សេងទៀតអោយក្រុមជំនុំអ្នកដែរឬទេ ? ។

ព្រះអំណោយទានសំរាប់ :

- នាំឱ្យមនុស្សមានបាបដឹងថា ខ្លួនមានកំហុស (១ កូរិនថូស ១៤:២៤-២៥) និង ដឹងពីឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ។
- បំរើព្រះជាម្ចាស់ និង អ្នកដទៃ ។
- កសាងព្រះកាយរបស់ព្រះគ្រីស្តអោយចំរើនឡើង គឺកសាងក្រុមជំនុំ ។
- បំពេញកិច្ចការក្នុងពិភពលោកថ្វាយព្រះជាម្ចាស់ ។

តើអ្នកណាត្រូវធ្វើការងារ ដើម្បីអោយក្រុមជំនុំរីកចំរើនឡើង ?

☐ គឺគ្រូអធិប្បាយ និង គ្រូគង្វាលតែប៉ុណ្ណោះ ។

☐ ពួកអ្នកជឿលើព្រះគ្រីស្តទាំងអស់ ។

សមាជិកម្នាក់ៗមានកិច្ចការបំរើរបស់ខ្លួនផ្ទាល់ នៅក្នុងក្រុមជំនុំ ។

ព្រះអំណោយទានខ្លះមានលក្ខណៈ «អស្ចារ្យមិនធម្មតា» ហើយ ព្រះអំណោយទានខ្លះទៀត មានលក្ខណៈ «ធម្មតា» ។ ព្រះជាម្ចាស់ធ្វើការអស្ចារ្យតាមរយៈគ្រីស្តជនខ្លះ ហើយព្រះអង្គត្រាស់ហៅមនុស្សខ្លះទៀតឱ្យបំរើព្រះអង្គ តាមរបៀបរស់នៅសាមញ្ញធម្មតា ដូចជាការបោសសំអាតកន្លែងថ្វាយបង្គំជាដើម ។

ក្នុងគ្រប់ករណីទាំងអស់ ត្រូវប្រើព្រះអំណោយទានគ្រប់យ៉ាង ដោយសេចក្តីស្រឡាញ់ និង ក្រោមការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រទានឱ្យគ្រីស្តជនចេះប្រើព្រះអំណោយទាននិមួយៗទាំងនោះ ។ នៅពេលដែលយើងប្រើព្រះអំណោយទាន ដែលយើងបានទទួល ព្រះជាម្ចាស់នឹងធ្វើអោយយើងរីកចំរើនឡើងខាងព្រះអំណោយទាននោះ ។

បំរើកិច្ចការជាអ្នកទទួលភ្ញៀវ ឬ អ្នកនាំភ្ញៀវរកកន្លែងអង្គុយដោយស្វាគមន៍ពួកអ្នកជឿថ្មី និង ភ្ញៀវជាពិសេស ដើម្បីអោយពួកគេមានអារម្មណ៍ថា ក្រុមជំនុំស្វាគមន៍ពួកគេ ដែលនាំអោយពួកគេចង់មកព្រះវិហារទៀត ? ។

ព្រះអំណោយទាន (ឬ ការប៉ិនប្រសប់) ខាងភ្លេង និង ចំរៀង ។

១ ក្រូនិចថ្ងៃ ១៤:២៦, ទំនុកតម្កើង ជំពូក ១៥០ ។

តើអ្នកណាអាចលេងឧបករណ៍ភ្លេង ?

តែងបទចំរៀង ?

ច្រៀងចំរៀងសរសើរតម្កើងពិសេស ក្នុងកម្មវិធីថ្វាយបង្គំ ? ។

ព្រះអំណោយទានខាងបកប្រែភាសាចំឡែកអស្ចារ្យ (ការពន្យល់អត្ថន័យរបស់ព្រះបន្ទូល ដែលគេថ្លែងជាភាសាដទៃ នៅក្នុងពេលប្រជុំ) ។

១ កូរិនថូស ១២:១០, ១ កូរិនថូស ១២:៣០,
១ កូរិនថូស ១៤:២៦-២៨ ។

តើអ្នកណាអាចបកប្រែព្រះបន្ទូល ដែលគេថ្លែងជាភាសាដទៃ ? ។

ព្រះអំណោយទានខាងទទួលភ្ញៀវ (ការផ្តល់កន្លែងស្នាក់នៅ និងចំណីអាហារ) ។

១ ពេត្រុស ៤:៩, រ៉ូម ១២:៩-១៣, រ៉ូម ១៦:២៣,
កិច្ចការ ១៦:១៤-១៥, ហេប្រឺ ១៣:១-២ ។

តើអ្នកណាអាចទទួលផ្តល់ទីកន្លែងស្នាក់នៅ និង ចំណីអាហារដល់គ្រីស្តជនអ្នកបំរើ ដែលមកពីកន្លែងផ្សេង ?

ទទួលកូនកំព្រា ឬ មនុស្សចាស់អោយនៅជាមួយ ?

ព្រះអំណោយទានសំរាប់បំពេញកិច្ចការថ្វាយព្រះជាម្ចាស់

☐ សូមអាន រ៉ូម ១២:៣-៥ ។ សូមគូសសញ្ញា «✓» នេះ ក្នុងប្រអប់ «☐» នេះ នៅពេលដែលអ្នកបានអានរួចហើយ ។

ហេតុអ្វីបានជាយើងមិនត្រូវលើកតម្លៃខ្លួនឯង ដោយសារតែបានទទួលព្រះអំណោយទានខាងព្រលឹងវិញ្ញាណ ? (ខ ៣) ។

តើអ្នកណាប្រទានព្រះអំណោយទានខាងព្រលឹងវិញ្ញាណដល់យើង ? ។

ហេតុអ្វីបានជាយើងទាំងអស់គ្នា មិនមានព្រះអំណោយទាន និងមុខងារ ដូចៗគ្នាទាំងអស់ ? (ខ ៤-៥) ។

ព្រះអំណោយទាន ដែលមានរៀបរាប់ខាងក្រោមនេះ ដកស្រង់ពី រ៉ូម ១២:៦-៨ និង ១ កូរិនថូស ជំពូក ១២ ។

សូមគូសសញ្ញា «✓» នេះ សំគាល់ព្រះអំណោយទានទាំងប៉ុន្មាន ដែលអ្នកប្រើច្រើនជាងគេក្នុងកិច្ចការបំរើរបស់អ្នក :

- ☐ ថ្លែងព្រះបន្ទូល (ប្រកាសព្រះបន្ទូលដែលព្រះជាម្ចាស់ដាក់ក្នុងចិត្ត)
- ☐ បំរើ (ជួយអ្នកដទៃ)
- ☐ បង្រៀន (បកស្រាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង ធ្វើអោយព្រះបន្ទូលនោះមានប្រយោជន៍ក្នុងជីវិតអ្នកស្តាប់)
- ☐ លើកទឹកចិត្ត (ដាស់តឿន និង ជំរុញអ្នកដទៃ)
- ☐ ចែកទ្រព្យរបស់ខ្លួន (អោយដោយចិត្តសប្បុរស)
- ☐ ដឹកនាំ (គ្រប់គ្រង ឬ ទទួលខុសត្រូវ)
- ☐ ចែកទានដល់ជនក្រីក្រ (ជួយអ្នកខ្វះខាត)
- ☐ និយាយប្រកបដោយប្រាជ្ញា (ការផ្តល់ដំបូន្មាន)

ព្រះអំណោយទានខាងនិយាយភាសាចំឡែកអស្ចារ្យ (ការនិយាយជាភាសាមួយ ដែលអ្នកនិយាយមិនធ្លាប់ដែលចេះ ហើយបើថ្លែងព្រាប់ក្រុមជំនុំ ត្រូវមានគេបកប្រែ) ។

១ កូរិនថូស ១២:១០, ១ កូរិនថូស ១២:២៨ និង ១៤:៤-២៥, កិច្ចការ ២:១-១៣, កិច្ចការ ១០:៤៤-៤៦, កិច្ចការ ១៩:១-៧, ម៉ាកុស ១៦:១៧ ។

កំណត់ចំណាំ : យោងទៅតាម ១ កូរិនថូស ១៤:២៦-២៨ នៅក្នុងការប្រជុំរបស់ក្រុមជំនុំ អាចមានមនុស្សថ្លែងព្រះបន្ទូលជាភាសាដទៃដល់ទៅបីនាក់ ហើយត្រូវបកប្រែព្រះបន្ទូលទាំងនេះដើម្បីកសាងក្រុមជំនុំអោយរីកចំរើនឡើង ។

តើអ្នកណាអាចថ្លែងព្រះបន្ទូលជាភាសាដទៃ ទៅក្រុមជំនុំ ? ។

ព្រះអំណោយទានខាងស្មង់មើលវិញ្ញាណល្អ ឬ វិញ្ញាណអាក្រក់ (ចេះបែងចែកកិច្ចការរបស់វិញ្ញាណអាក្រក់ ពីកិច្ចការរបស់ព្រះ-វិញ្ញាណព្រះជាម្ចាស់) ។

១ កូរិនថូស ១២:១០, កិច្ចការ ៥:១-១១ និង ១៦:១៦-១៨, ១ យ៉ូហាន ៤:១-៦, ម៉ាថាយ ១៦:២១-២៣ ។

តើអ្នកណាអាចប្រាប់ពួកអ្នកជឿអោយដឹងមុនអំពីឆ្កែចចក ដែលនឹងមកធ្វើអោយក្រុមជំនុំបែកបាក់គ្នា ?

មើលអោយដឹង ហើយបដិសេធគោលជំនឿក្លែងក្លាយគ្រប់យ៉ាង ឬ កំហុសផ្សេងៗទៀត ?

ចេះបែងចែកឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ពីឫទ្ធានុភាពរបស់វិញ្ញាណអាក្រក់ ?

ចេះបែងចែកព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ពីការរំជួលចិត្តខាងសាច់ឈាម ? ។

☐ និយាយដោយយល់គំរោងការដ៏លាក់កំបាំងរបស់ព្រះជាម្ចាស់

☐ មានជំនឿ (ដើម្បីចេះព្យាយាមអធិស្ឋានគ្រប់យ៉ាង)

☐ ប្រោសមនុស្សអោយជាពីជម្ងឺ

☐ ធ្វើការអស្ចារ្យ

☐ ស្មង់មើលវិញ្ញាណល្អ ឬ វិញ្ញាណអាក្រក់

☐ និយាយភាសាចំឡែកអស្ចារ្យ

☐ ចេះបកប្រែភាសាចំឡែកអស្ចារ្យ ។

© Project WorldReach © SEAN

ព្រះជាម្ចាស់ប្រទានព្រះអំណោយទានទៅអ្នកជឿផ្សេងៗគ្នា

អាន ១ កូរិនថូស ជំពូក ១២, ១៣ និង ១៤ ។

សាវ័កប៉ូលកែតម្រូវកំហុសខ្លះរបស់ពួកគ្រីស្តជន នៅក្រុងកូរិនថូស ក្នុងការប្រើប្រាស់ព្រះអំណោយទាន ។ គាត់បង្រៀនពួកគេពីរបៀបប្រើព្រះអំណោយទានដែលត្រឹមត្រូវ ។

ហេតុអ្វីបានជាគ្រីស្តជនមិនត្រូវប្រើព្រះអំណោយទាន ដើម្បីធ្វើឱ្យមានការបែកបាក់គ្នា ? (១ កូរិនថូស ១២:៤-១១)

☐ ព្រោះព្រះជាម្ចាស់តែមួយ ដែលប្រទានព្រះអំណោយទានទាំងអស់ ។

☐ ព្រោះមានព្រះអំណោយទានខ្លះមានប្រយោជន៍ជាង ។

តើសាវ័កប៉ូលប្រៀបប្រដូចសមាជិកក្រុមជំនុំ ទៅនឹងអ្វី ?
(១ កូរិនថូស ១២:១២-២៦)

☐ ទៅនឹងពួកព្យាការី និង ស្តេចដែលខ្លាំងពូកែ ។

☐ ទៅនឹងផ្នែកផ្សេងៗនៃរូបកាយរបស់មនុស្សម្នាក់ៗ ។

ព្រះអំណោយទានខាងជ្រោសជម្ងឺ (ដោយសារឫទ្ធានុភាពរបស់ព្រះជាម្ចាស់) ។

១ កូរិនថូស ១២:៩-១០, ២៨, កិច្ចការ ៣:១-១០,
កិច្ចការ ៥:១២-១៦, កិច្ចការ ៩:៣២-៣៥,
កិច្ចការ ២៨:៧-១០ ។

តើអ្នកណាអាចអធិស្ឋានសំរាប់អ្នកជម្ងឺ ដើម្បីសូមអោយព្រះជាម្ចាស់ជ្រោសពួកគេអោយជាសះស្បើយ ? ។

ព្រះអំណោយទានខាងធ្វើការអស្ចារ្យ (ទីសំគាល់សំរាប់បញ្ជាក់ដំណឹងល្អ និង ដើម្បីថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់) ។

១ កូរិនថូស ១២:១០, ១ កូរិនថូស ១២:២៨,
កិច្ចការ ៩:៣៦-៤២, កិច្ចការ ១៩:១១-២០ និង ២០:៧-១២,
រ៉ូម ១៥:១៨-១៩, ២ កូរិនថូស ១២:១២ ។

តើនៅក្នុងកិច្ចការបំរើរបស់អ្នកណា ដែលមានការអស្ចារ្យកើតឡើង ? ។

ព្រះអំណោយទានខាងជំនឿ (អធិស្ឋានប្រកបដោយប្រសិទ្ធិភាព និង សំរេចកិច្ចការធំៗថ្វាយព្រះជាម្ចាស់) ។

១ កូរិនថូស ១២:៩, ១ កូរិនថូស ១៣:២, ម៉ាថាយ ១៧:២០, ម៉ាថាយ ២១:២១-២២, កិច្ចការ ១១:២២-២៤, កិច្ចការ ២៧:២១-២៥, ហេប្រឺ ជំពូក ១១, រ៉ូម ៤:១៨-២១ ។

តើអ្នកណាអាចអធិស្ឋានសំរាប់សេចក្តីត្រូវការពិសេស ?

អធិស្ឋានទូលអង្វរសំរាប់អ្នកដទៃ ?

ទូលសូមអោយព្រះជាម្ចាស់ជួយសមាជិករដ្ឋាភិបាល ?

អធិស្ឋានទូលសូមអោយពួកអ្នកដែលនៅសង្ស័យ និង មានចិត្តព្រួយបារម្ភ មានលំនឹងក្នុងចិត្តវិញ ? ។

តើអ្នកណាប្រទានព្រះអំណោយទានផ្សេងៗដល់គ្រីស្តបរិស័ទ ដែលជាសរីរាង្គរបស់ព្រះកាយព្រះគ្រីស្ត ? (១ កូរិនថូស ១២:១៨)

☐ គ្រូគង្វាល ។

☐ គណៈកម្មាធិការរបស់ក្រុមជំនុំ ។

☐ ព្រះជាម្ចាស់ ។

☐ សាវ័កប៉ូល ។

ព្រះជាម្ចាស់ប្រទានព្រះអំណោយទានទាំងឡាយ ស្របតាមព្រះ-ហឫទ័យព្រះអង្គផ្ទាល់ ។

តើយើងអាចដឹងថា យើងមានព្រះអំណោយទានអ្វីខ្លះ ដោយរបៀបណា ? គឺដោយបំពេញកិច្ចការផ្សេងៗថ្វាយព្រះគ្រីស្ត ដោយស្មោះត្រង់ ។ កិច្ចការបំរើដែលយើងបំពេញបានល្អជាងគេ ជាព្រះអំណោយទានរបស់យើងហើយ ។ ក្រុមជំនុំសកម្មតែងតែផ្តល់ឱកាសអោយអ្នកជឿទាំងអស់អាចប្រើអំណោយទានរបស់ខ្លួន ។ ឱកាសដូចនេះ ជួយអោយសមាជិកម្នាក់ៗអាចរកឃើញកិច្ចការបំរើដែលព្រះជាម្ចាស់ប្រទានអោយគេធ្វើ ។

ព្រះអំណោយទានទាំងឡាយ កសាងព្រះកាយទាំងមូលអោយជីវិតឡើង ។ ព្រះជាម្ចាស់ប្រទានព្រះអំណោយទានទាំងឡាយ ស្របទៅតាមសេចក្តីត្រូវការរបស់ក្រុមជំនុំ ដើម្បីអោយក្រុមជំនុំកាន់តែមានសេចក្តីស្រឡាញ់ និង ឯកភាពគ្នា ។ ក្រុមជំនុំមួយនឹងនៅទ្រឹងមិនរីកចំរើនទៅមុខ បើសិនជាមិនអនុញ្ញាតអោយសមាជិកទាំងអស់ មានសេរីភាពអាចបំពេញកិច្ចការបំរើរបស់ខ្លួនទេ ។

ព្រះជាម្ចាស់ប្រទានព្រះអំណោយទានអោយយើង នៅពេលដែលយើងត្រូវការ ។ ឧទាហរណ៍ លោកភីលីពចាប់ផ្តើមមានព្រះអំណោយទានខាងបំរើ នៅពេលដែលគាត់ជួយអ្នកខ្វះខាត (កិច្ចការ ៦:១-៦) ។ ក្រោយមក គាត់ប្រើព្រះអំណោយទានខាងផ្សាយដំណឹងល្អ និង ធ្វើការអស្ចារ្យ (កិច្ចការ ៨:៤-៣៨) ។

តើអ្នកជឿទាំងអស់ សុទ្ធតែបានទទួលព្រះអំណោយទានគ្រប់ៗគ្នាដែរឬទេ ? (១ កូរិនថូស ១២:៧) ។ _____

តើយើងទទួលព្រះអំណោយទាន ដើម្បីធ្វើអ្វី ? (ខ ៧)

☐ ដើម្បីអោយយើងអាចដឹងខ្លួនថា យើងជាមនុស្សសំខាន់ ។

☐ ដើម្បីអោយអ្នកដទៃរាប់យើងជាមនុស្សសំខាន់ ។

☐ ដើម្បីជាប្រយោជន៍រួម និង ថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ។

ផ្តល់ដំបូន្មានអោយពួកយុវជនដែលមានបញ្ហា ?

_____

ផ្តល់ដំបូន្មានអោយគូដណ្តឹង ឬ គូស្វាមីភរិយាដែលមានបញ្ហា ?

_____

កំណត់គំរោងពិសេសផ្សេងៗ ស្របតាមសេចក្តីត្រូវការរបស់ក្រុមជំនុំ ? ។

_____

ព្រះអំណោយទានខាងនិយាយដោយយល់គំរោងការដ៏លាក់កំបាំង (មើលស្គាល់ និង បង្រៀនអំពីសេចក្តីពិតខាងព្រលឹងវិញ្ញាណ) ។

១ កូរិនថូស ២:១៤, ១ កូរិនថូស ១២:៨, កិច្ចការ ៥:១-១១, កូឡូស ២:២-៣, ២ កូរិនថូស ១១:៦, យ៉ូហាន ៤:១៧-១៨ ។

តើអ្នកណាអាចរកឱ្យឃើញសេចក្តីត្រូវការទាំងឡាយរបស់ក្រុមជំនុំ ដើម្បីឱ្យពួកអ្នកដឹកនាំអាចបំពេញសេចក្តីត្រូវការទាំងនោះ ?

_____

មានសមត្ថភាព អាចកំណត់មូលហេតុនៃបញ្ហាផ្ទាល់ខ្លួនរបស់មនុស្ស ? ។

_____

© Project WorldReach © SEAN

សម្រុះសម្រួលបងប្អូនរួមជំនឿ ដែលទាស់ទែងខ្វែងគំនិតគ្នា ?

ពិនិត្យមើលហ្វូងចៀមទាំងមូល ដើម្បីការពារកុំឱ្យមានបញ្ហា និង
កុំអោយ «ឆ្កែចចក »អាចចូលមកបាន ?

បង្ហាត់បង្រៀនពួកអ្នកដឹកនាំ និង អ្នកជំនួយ ? ។

**ព្រះអំណោយទានខាងនិយាយប្រកបដោយប្រាជ្ញា(ការផ្តល់ដំបូន្មាន
ដោយប្រាជ្ញា ដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រទានអោយ) ។**

១ កូរិនថូស ២:១-១៣, ១ កូរិនថូស ១២:៨, កិច្ចការ ៦:៣,
យ៉ាកុប ១:៥-៦, ២ ពេត្រុស ៣:១៥ ។

តើអ្នកណាអាចផ្តល់ដំបូន្មានអោយពួកអ្នកដែលមានបញ្ហា ?

ផ្តល់ដំបូន្មានអោយគ្រីស្តជនដែលជួយធ្វើការក្នុងក្រុមជំនុំ ?

ព្រះអំណោយទានមិនមែនសំរាប់
អោយយើងលើកតម្កើងខ្លួន ឬ
ទាក់ទាញអ្នកដទៃអោយ
ចាប់អារម្មណ៍លើយើងទេ
តែសំរាប់កសាងក្រុមជំនុំ
ទាំងមូលអោយរីកចំរើនឡើង ។



ព្រះអំណោយទានទាំងឡាយ ជួយយើងអោយអាចបំពេញមុខងារ
ដូចជាអវយវៈរបស់រូបកាយមួយ ។ ក្រុមជំនុំជាព្រះកាយរបស់
ព្រះគ្រីស្ត ឯយើងជាអវយវៈរបស់ព្រះកាយនោះវិញ គឺយើងជាដៃ
ជើង ស្លឹកត្រចៀក ។ល។ ។ នៅក្នុងរូបកាយ ដែលមានសុខ-
ភាពល្អ អវយវៈផ្សេងៗអាចធ្វើសកម្មភាព តាមការចាត់ចែងរបស់
ក្បាល ។ ព្រះសិរសារបស់ក្រុមជំនុំ គឺព្រះយេស៊ូ ។ ក្រុមជំនុំ
មួយអាចបំរើព្រះគ្រីស្តបាន បើសិនជាយើងជាសមាជិកចេះធ្វើ
ការងារជាមួយគ្នាដោយស៊ីសង្វាក់គ្នា និង ដោយស្តាប់បង្គាប់ព្រះ-
សិរសារបស់យើង ។ ព្រះវិញ្ញាណដ៏វិសុទ្ធមិនមែនប្រទានព្រះ-
អំណោយទានអោយយើង ដើម្បីសិរីរុងរឿងរបស់យើងជាអ្នកបំរើ
ទេ តែដើម្បីសិរីរុងរឿងរបស់ព្រះយេស៊ូគ្រីស្តវិញទេ (យ៉ូហាន
១៥:២៦-២៧ និង ១៦:១៣-១៤) ។

ព្រះវិញ្ញាណដ៏វិសុទ្ធថ្វាយសិរីរុងរឿងទៅ :

☐ ព្រះអង្គផ្ទាល់ ។

☐ ព្រះអម្ចាស់យេស៊ូគ្រីស្ត ។

☐ យើងរាល់គ្នា ។



ព្រះអំណោយទានជាគ្រូគង្វាល (ឃ្វាលហ្វូងចៀម) ។

អេភេសូ ៤:១១-១៤, ១ ធីម៉ូថេ ៣:១-៧,
យ៉ូហាន ១០:១-១៨, ១ ពេត្រុស ៥:១-៣ ។

តើអ្នកណាអាចស្វែងរកចៀម ដែលវង្វែងចេញពីព្រះជាម្ចាស់ ឬ មិនមកចូលរួមថ្វាយបង្គំ ?

អោយចំណីខាងព្រលឹងវិញ្ញាណ ដែលជាព្រះបន្ទូលរបស់ព្រះជា-ម្ចាស់ដល់ហ្វូងចៀម ?

ដឹកនាំក្រុមជំនុំទៅតាមមាគ៌ារបស់ព្រះជាម្ចាស់ ?

ធ្វើពិធីជ្រមុជទឹក និង ដឹកនាំពិធីកាច់នំបុ័ង ?

ធ្វើកិច្ចការបំរើជាគំរូ ដើម្បីបណ្តាលចិត្តសមាជិកឱ្យធ្វើការងារថ្វាយព្រះគ្រីស្ត ?

នាំពួកអ្នកជឿថ្មីទៅផ្សាយដំណឹងល្អអំពីព្រះគ្រីស្ត ប្រាប់សាច់ញាតិ និង មិត្តភក្តិរបស់ពួកគេ ?

ប្រកាសដំណឹងល្អអំពីការសង្គ្រោះដោយសារព្រះគ្រីស្ត តាមវិទ្យុ សារពត៌មាន ទស្សនាវត្តី ខិត្តប័ណ្ណ អត្ថបទ ។ល។ ?

ទៅសួរសុខទុក្ខពួកអ្នកជឿថ្មី ដើម្បីណែនាំ និង លើកទឹកចិត្តពួកគេ ?

បណ្តុះបណ្តាលអ្នកជឿឯទៀត អោយធ្វើការផ្សាយដំណឹងល្អដែរ ? ។

ព្យាការីដែលមិនចេះដឹងពីសេចក្តីបង្រៀនអំពីព្រះអំណោយទាន តែងតែគិតថា មានតែកិច្ចការថ្លែងព្រះបន្ទូលរបស់គាត់ប៉ុណ្ណោះដែលសំខាន់ ហើយគាត់ខិតខំប្រើអំណាចលើក្រុមជំនុំ ។

តាមពិត សមាជិកម្នាក់ៗមានព្រះអំណោយទានសំរាប់បំពេញមុខងារបំរើរៀងៗខ្លួន ។ យើងត្រូវជួយសមាជិកទាំងអស់ អោយអាចដឹងពីព្រះអំណោយទានរបស់ពួកគេម្នាក់ៗ ព្រមទាំងណែនាំឱ្យពួកគេម្នាក់ៗចេះបំរើព្រះជាម្ចាស់ ដោយព្រះអំណោយរបស់ពួកគេ ។ សូម្បីតែសមាជិកដែលទន់ទាបជាងគេបំផុត ក៏មានព្រះអំណោយទាន ហើយត្រូវមានការទទួលខុសត្រូវក្នុងព្រះកាយដែរ ។



តើគ្រូគង្វាលដែលយល់ខុស ធ្វើដូចម្តេច ?

☐ លើកទឹកចិត្តសមាជិកឱ្យចេះប្រើព្រះអំណោយទានរបស់ខ្លួន ។

☐ ធ្វើអោយរាំងស្ទះ ឬ ភ្លេចនាំអោយសមាជិកចេះប្រើព្រះ-អំណោយទានរបស់ពួកគេ ។

គ្រូវប្រយ័ត្នចំពោះសមាជិក ដែលស្វែងរកអំណោយទានខាងព្រលឹងវិញ្ញាណ ដើម្បីអោយអ្នកឯទៀតចាប់អារម្មណ៍លើខ្លួន ។ ព្រះអម្ចាស់យេស៊ូបានប្រាប់យើងអោយដឹងថា សូម្បីតែមនុស្សអាក្រក់ ក៏អាចធ្វើការអស្ចារ្យក្នុងព្រះនាមព្រះអង្គដែរ (ម៉ាថាយ ៧:២១-២៣) ។

ការថ្លែងពាក្យទំនាយជាព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ប៉ុន្តែ ព្រះយេស៊ូបានប្រាប់យើងថា មានពាក្យទំនាយក្លែងក្លាយដែរ ។ ការធ្វើជាគ្រូគង្វាល ជាព្រះអំណោយទានមួយ ប៉ុន្តែ ព្រះគម្ពីរប្រាប់យើងអោយចេញអោយឆ្ងាយពីគ្រូគង្វាលក្លែងក្លាយ គ្រូបង្រៀនក្លែងក្លាយ និង សាវ័កក្លែងក្លាយ ។

មារសាតាំងអាចធ្វើត្រាប់តាមព្រះអំណោយទានគ្រប់យ៉ាង ។ ព្រះយេស៊ូប្រាប់យើងអោយដឹងថា យើងអាចមើលស្គាល់ព្យាការីពិតដោយសារផលផ្លែរបស់ពួកគេ ។

ព្រះអំណោយទានជាគ្រីស្តទូត (ត្រូវបានព្រះជាម្ចាស់ត្រាស់ហៅអោយចេញទៅផ្សាយដំណឹងល្អ និង បង្កើតក្រុមជំនុំថ្មី) ។

អេភេសូ ៤:១១-១២, ១ កូរិនថូស ៣:៦-១០,
១ កូរិនថូស ៩:១៩-២៣, ១ កូរិនថូស ១២:២៨,
២ កូរិនថូស ៥:២០-៦:១០ កិច្ចការ ១៤:២១, រ៉ូម ១០:១៥ ។

តើអ្នកណាអាចបង្កើតក្រុមជំនុំសាខាថ្មី ?

_____

ចេញទៅធ្វើជាគ្រីស្តទូតនៅបរទេស ? ។

_____

ព្រះអំណោយទានជាអ្នកផ្សាយដំណឹងល្អ (ប្រកាសដំណឹងល្អ ធ្វើទីបន្ទាល់អំពីព្រះយេស៊ូគ្រីស្ត) ។

អេភេសូ ៤:១១-១៤, ២ ធីម៉ូថេ ៤:៥, កិច្ចការ ៨:៥-៦,
កិច្ចការ ៨:២៦-៤០, កិច្ចការ ២១:៨ ។

តើអ្នកណាអាចពន្យល់ដំណឹងល្អយ៉ាងច្បាស់លាស់ ដោយសេចក្តីស្រឡាញ់ និង ដោយអំណាច ?

_____

_____

ព្រះអំណោយទានខាងបង្ហាញសេចក្តីមេត្តាករុណា (ជួយអ្នកខ្វះខាត អ្នកជម្ងឺ អ្នកធ្លាក់ទឹកចិត្ត ឬ អ្នកបែរចេញពីព្រះអង្គ) ។

រ៉ូម ១២:៨, ម៉ាកុស ៩:៤១, កិច្ចការ ១១:២៨-៣០,
កិច្ចការ ១៦:៣៣-៣៥, លូកា ១០:៣៣-៣៥,
ម៉ាថាយ ២០:២៩-៣៤, ម៉ាថាយ ២៥:៣៤-៤០ ។

តើអ្នកណាអាចជួយអ្នកខ្វះខាត អ្នកជម្ងឺ ឬ អ្នកធ្លាក់ទឹកចិត្ត ?

_____

_____

ទៅសួរសុខទុក្ខស្ត្រីមេម៉ាយ កូនកំព្រា អ្នកជាប់ក្នុងពន្ធនាគារ ឬ អ្នកជម្ងឺ ?

_____

_____

ជួយអ្នកជឿដែលធ្លាក់ក្នុងសេចក្តីល្បួង អោយមានសភាពដូចដើមវិញ ? ។

_____

_____

_____

ព្រះអំណោយទានពិត ដែលមកពីព្រះជាម្ចាស់ បង្រួបបង្រួម និង កសាងក្រុមជំនុំឱ្យចេះស្តាប់បង្គាប់ព្រះអម្ចាស់យេស៊ូគ្រីស្ត ដោយស្រុះស្រួលគ្នា និង ស្រឡាញ់គ្នា ។ រីឯពួកអ្នកដែលមានព្រះអំណោយទានក្លែងក្លាយមកពីអារក្ស នាំអោយក្រុមជំនុំមានអំនួត និង បែកបាក់គ្នា ។



បុទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ មិនមែនជារបៀបនិយាយស្រែកអោយឮខ្លាំងៗខាងសាច់ឈាមនោះទេ ! ។

ព្រះជាម្ចាស់ប្រទានអោយអ្នកជឿគ្រប់គ្នា មានឫទ្ធានុភាពអាចប្រើព្រះអំណោយទានរបស់ខ្លួន ។ នេះទើបជាឫទ្ធានុភាពខាងព្រលឹងវិញ្ញាណ ។

គេអាចមើលឃើញឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុង :

☐ លទ្ធផលល្អនៃកិច្ចការបំរើរបស់យើង ។

☐ សម្រែកខ្លាំងៗរបស់យើង ។

សូមកុំច្រឡំព្រះអំណោយទាន និង ផលផ្លែរបស់ព្រះវិញ្ញាណ ។ អ្នកជឿមានព្រះអំណោយទានផ្សេងៗគ្នា ។ តែអ្នកជឿទាំងអស់មានផលផ្លែរបស់ព្រះវិញ្ញាណដូចគ្នាទាំងអស់ ។ ផលផ្លែរបស់ព្រះវិញ្ញាណ គឺសេចក្តីស្រឡាញ់ សេចក្តីសុខសាន្ត អំណរ និង គុណសម្បត្តិផ្សេងៗទៀត ដែលព្រះយេស៊ូគ្រីស្តប្រោសប្រទានដល់អ្នកជឿដែលស្ថិតនៅជាប់ជាមួយព្រះអង្គ (កាឡាទី ៥:២២-២៣) ។ ផលផ្លែទាំងនេះ ជាចរិតលក្ខណៈរបស់ព្រះយេស៊ូគ្រីស្ត ដែលគង់ក្នុងយើង ។

រៀបចំធ្វើ ឬ ចាត់ចែងកម្មវិធីបង្រៀនមួយសំរាប់ក្រុមជំនុំ ?

ចាត់ចែងកម្មវិធីមួយអំពីការផ្សាយដំណឹងល្អ ដោយទៅសួរសុខទុក្ខក្រុមគ្រួសារ មួយម្តងៗ ?

ជួយអោយសមាជិកទាំងឡាយព្រមព្រៀងគ្នារៀបចំផែនការ និង គោលដៅសំរាប់ក្រុមជំនុំ ?

វាយតំលៃការងាររបស់ក្រុមជំនុំ ដើម្បីវាស់ស្ទង់ការរីកចំរើនរបស់ការងារទាំងនេះ និង ធ្វើឱ្យការងារទាំងនេះ កាន់តែរីកចំរើនឡើង និង កាន់តែមានប្រសិទ្ធភាពថែមទៀត ?

ដឹកនាំក្រុមដែលបំពេញមុខងារបំរើមួយ (ឧទាហរណ៍ ក្រុមចំរៀង ឬ ក្រុមភ្លេង) ? ។

© Project WorldReach © SEAN

ព្រះអំណោយទានជាអ្នកដឹកនាំ (ខាងការគ្រប់គ្រងក្រុមជំនុំ ការចាត់ចែង ការជួយសមាជិកទាំងអស់អោយចេះធ្វើការងារ ដោយឯកភាពជារួបកាយរួមតែមួយ ការបង្កើតគោលដៅ និង ការអនុវត្តផែនការ ដើម្បីសំរេចគោលដៅទាំងនោះ) ។

១ ធីម៉ូថេ ៥:១៧, កិច្ចការ ៦:១-៧, កិច្ចការ ៧:១០,
រ៉ូម ១២:៨, ហេប្រឺ ១៣:១៧, លូកា ៩:៥១-៥២,
លូកា ១៤:២៨-៣០, ១ កូរិនថូស ១២:២៨, ទីតុស ១:៥ ។

តើអ្នកណាអាចនាំអោយមានទំនាក់ទំនងល្អ ពេញដោយសេចក្តីស្រឡាញ់ រវាងសមាជិកទាំងអស់របស់ក្រុមជំនុំ ?

រៀបចំធ្វើ និង ចាត់ចែងការងាររបស់ក្រុមជំនុំ ដើម្បីអោយសមាជិកទាំងអស់ធ្វើការងាររួមគ្នាដោយស្រុះស្រួលគ្នាជារួបកាយតែមួយ ?

រៀបចំយុវជន ស្ត្រី និង បុរសឱ្យធ្វើការងារថ្វាយព្រះអម្ចាស់ ?

អស់អ្នកជឿដែលមានព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំ មាន :

☐ ព្រះអំណោយទានដូចគ្នា ។

☐ ផលផ្លែរបស់ព្រះវិញ្ញាណដូចគ្នា ។

គ្រីស្តជនគ្រប់គ្នាអាចមានផលផ្លែនៃព្រះវិញ្ញាណដូចគ្នា តែព្រះជាម្ចាស់ប្រទានអោយពួកគេមានព្រះអំណោយទានផ្សេងៗគ្នា ។

ផលផ្លែនៃព្រះវិញ្ញាណ គឺចរិតលក្ខណៈរបស់គ្រីស្តជន ។ រីឯព្រះអំណោយទាន ជាសមត្ថភាពពិសេស ដែលព្រះជាម្ចាស់ប្រទានឱ្យគ្រីស្តជន ដើម្បីអោយពួកគេអាចធ្វើការងារថ្វាយព្រះអង្គ ។ គ្រីស្តជនម្នាក់អាចមានព្រះអំណោយទាន ដោយមិនទាន់មានផលផ្លែនៃព្រះវិញ្ញាណច្រើន ក្នុងចរិតលក្ខណៈរបស់គាត់ទេ ។ គ្រីស្តជនត្រូវខិតខំអោយមានផលផ្លែរបស់ព្រះវិញ្ញាណសិន មុននឹងខិតខំអោយមានអំណោយទានច្រើន ។ ផលផ្លែនៃព្រះវិញ្ញាណទាំងអស់ ត្រូវផុសចេញពីសេចក្តីស្រឡាញ់របស់អ្នកជឿ បានសេចក្តីថា អ្នកដែលបំរើព្រះអម្ចាស់ ដោយព្រះអំណោយទាន ត្រូវមានជីវិត ពេញដោយសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ បើមិនដូច្នោះទេ ព្រះអំណោយទាននឹងគ្មានប្រយោជន៍ទេ ។

តើមួយណាសំខាន់ជាង ?

☐ ផលផ្លែរបស់ព្រះវិញ្ញាណ ។

☐ ព្រះអំណោយទានរបស់ព្រះវិញ្ញាណ ។

សូមប្រៀបធៀបចំលើយរបស់អ្នកជាមួយ ១ កូរិនថូស ១២:៣១, ១៣:១-៣ ។

ព្រះអំណោយទានខាងចែកទ្រព្យរបស់ខ្លួន (ចែកដោយអំណរ និងដោយអស់ពីចិត្ត សំរាប់សេចក្តីត្រូវការពិសេសៗ) ។

រ៉ូម ១២:៨, ២ កូរិនថូស ជំពូក ៨, ២ កូរិនថូស ជំពូក ៩, ម៉ាកុស ១២:៤១-៤៤ ។

តើអ្នកណាអាចចែកទ្រព្យរបស់ខ្លួន ដោយអំណរអស់ពីចិត្ត និងដោយមិនអោយមនុស្សច្រើនដឹង ?

លើកទឹកចិត្តឱ្យពួកអ្នកជឿដាក់ដង្វាយកាន់តែអស់ពីចិត្ត ?

រៀបចំធ្វើការងារ ឬ សកម្មភាព ដើម្បីរកប្រាក់ចំណូល ? ។

ព្រះអំណោយទានខាងដាស់តឿន (ដោយលើកទឹកចិត្ត និង ជំរុញ ពួកអ្នកជឿឱ្យធ្វើការងារ និង រស់នៅដើម្បីព្រះគ្រីស្ត) ។

រ៉ូម ១២:៨, ១ ធីម៉ូថេ ៤:១៣, ហេប្រឺ ១០:២៥,
កិច្ចការ ១៤:២២ ។

តើអ្នកណាអាចលើកទឹកចិត្តពួកអ្នកជឿ អោយរស់នៅ និង ធ្វើការងារ ដើម្បីព្រះគ្រីស្ត ?

លើកទឹកចិត្តគ្រីស្តជនអ្នកបំរើ នៅពេលដែលពួកគេធ្លាក់ទឹកចិត្ត ឬ ខ្ជិល ?

កែតម្រូវគ្រីស្តជនដែលមានកំហុស ?

ជួយលើកទឹកចិត្តអោយក្លាហានឡើង ពេលមានគ្រោះថ្នាក់ ឬ មានបញ្ហា ?

ធ្វើផ្ទាំងក្រដាសដែលមានសរសេរខគម្ពីរ ឬ ពាក្យលើកទឹកចិត្ត សំរាប់បិទ ឬ ព្យួរនៅទីប្រជុំ ? ។

ព្រះអំណោយទានទាំងឡាយ និង កិច្ចការ បំរើខាងព្រះអំណោយទាននិមួយៗនោះ

នៅពេលដែលអ្នកបានបង្រៀនក្រុមជំនុំរបស់អ្នក អំពីព្រះអំណោយទាន និង ផលផ្លែរបស់ព្រះវិញ្ញាណហើយ សូមសរសេរឈ្មោះសមាជិកដែលសំដែងព្រះអំណោយទានមួយ ក្បែរកិច្ចការបំរើដែលត្រូវនឹងព្រះអំណោយទាននោះ នៅក្នុងបញ្ជី នៅទំព័របន្តបន្ទាប់ទៅនេះ ។ បើសិនជាមិនទាន់មានសមាជិកបំពេញកិច្ចការបំរើណាមួយ សូមទុកចន្លោះក្បែរកិច្ចការបំរើនោះចំហសិន ។ ត្រូវជួយអ្នកជឿគ្រប់គ្នាឱ្យអាចទទួលបានព្រះអំណោយទាន ហើយប្រើ និង ធ្វើអោយព្រះអំណោយទាន ដែលព្រះជាម្ចាស់ប្រទានអោយនោះរីកចំរើនឡើង (១ កូរិនថូស ១៤:១) ។

ព្រះអំណោយទានខាងបំរើ (ជួយអ្នកដទៃ) ។

លូកា ៨:២-៣, ម៉ាកុស ១៥:៤០-៤១, រ៉ូម ១២:៧, រ៉ូម ១៦:១-២, ១ កូរិនថូស ១២:២៨, ២ ធីម៉ូថេ ១:១៦-១៨, កិច្ចការ ៦:១-៧, កិច្ចការ ៩:៣៦, ទីតុស ៣:១៣-១៤, កាឡាទី ៦:១០ ។

តើអ្នកណាអាចបំពេញកិច្ចការបំរើខាងក្រោមនេះ ? (សូមសរសេរឈ្មោះអ្នកទាំងនោះ) :

ធ្វើកិច្ចការពិសេសមួយ ដើម្បីជួយមនុស្សចាស់ ឬ អ្នកជម្ងឺ ?

សាងសង់ ថែរក្សា ឬ ជួសជុលទីកន្លែងថ្វាយបង្គំ ?

សំអាតទីកន្លែងថ្វាយបង្គំ ?

សរសេរសំបុត្រ ឬ ចម្លងមេរៀន ?

ត្រូវប្រើប្រាស់ព្រះអំណោយទានខាងបង្រៀន ដើម្បី :

☐ បង្កើតសាវ័កសកម្ម ។

☐ បង្កើតអ្នកសិក្សាដែលសិក្សាតែមេរៀន ។

តើអ្នកណាអាចបង្រៀនពួកអ្នកជឿថ្មីអោយក្លាយជាសាវ័ក ដោយជួយពួកគេឱ្យចេះប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ ?

ប្រព្រឹត្តខ្លួនជាអ្នកដឹកនាំ ដោយបង្រៀន និង ដឹកនាំមនុស្សដោយប្រើព្រះបន្ទូលព្រះជាម្ចាស់ ?

សរសេរមេរៀនសំរាប់ការសិក្សាព្រះគម្ពីរ ?

បង្រៀននិស្សិតគ្រូគង្វាល ?

ណែនាំកុមារអោយដើរតាមមាគ៌ារបស់ព្រះជាម្ចាស់ ? ។

© Project WorldReach © SEAN

កំណត់ចំណាំ : ពាក្យទំនាយដែលមកពីព្រះជាម្ចាស់ សុទ្ធតែស្របនឹងសេចក្តីចែងរបស់ព្រះគម្ពីរ ។ ព្រះជាម្ចាស់មិនដែលមានបន្ទូលប្រឆាំងនឹងព្រះអង្គទ្រង់ផ្ទាល់ទេ ។ សមាជិកទាំងអស់របស់ក្រុមជំនុំត្រូវពិចារណាមើលអំពីពាក្យទំនាយ ដែលសមាជិកណាម្នាក់បានថ្លែង (១ កូរិនថូស ១៤:២៩) ។

ព្រះអំណោយទានខាងបង្រៀន (ដើម្បីបង្កើតសាវ័កស្មោះត្រង់របស់ព្រះយេស៊ូគ្រីស្ត) ។

រ៉ូម ១២:៧, ១ កូរិនថូស ១២:២៨, អេភេសូ ៤:១១-១៤, កូឡូស ៣:១៦, កិច្ចការ ១៨:២៤-២៨, ២០:២០-២១ ។

ព្រះអំណោយទានខាងបង្រៀន មិនមែនគ្រាន់តែផ្តល់មេរៀនដល់អ្នកសិក្សាអោយបានច្រើនប៉ុណ្ណោះទេ ។ ព្រះគម្ពីរហាមមិនអោយយើងគ្រាន់តែស្តាប់ព្រះបន្ទូលប៉ុណ្ណោះទេ (យ៉ាកុប ១:២២) ។ គ្រូបង្រៀនព្រះគម្ពីរបង្កើតសាវ័ក ដោយបង្រៀនពួកគេអោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះយេស៊ូគ្រីស្ត ចំពោះយើង ។

គ្រូបង្រៀនដែលប្រើប្រាស់ព្រះអំណោយទានខាងបង្រៀនត្រឹមត្រូវប្រព្រឹត្តខ្លួនជាអ្នកដឹកនាំ ឬ ធ្វើការងារជាគំរូ ដើម្បីអោយពួកសាវ័កដែលគាត់បង្កើត ធ្វើតាមគាត់ និង ចូលរួមធ្វើការងារដែរ ។

ធ្វើរបងព័ទ្ធជុំវិញទីធ្លាព្រះវិហារ ឬ មើលថែសួនព្រះវិហារ ?

រកផ្កាសំរាប់ដាក់តាំងពេលថ្វាយបង្គំ ឬ តុបតែងបន្ទប់ ?

រៀបចំអ្វីៗដែលត្រូវការសំរាប់ធ្វើពិធីកាច់នំប៉័ង ?

ដើរបំពេញកិច្ចការសំរាប់ក្រុមជំនុំ (ដូចជាទៅយកលិខិត ទទួលទំនិញ ។ល។) ?

ធ្វើជាហេរញ្ញិក លេខា ឬ អ្នកជំនួយ ?

មើលថែទាំកុមារតូចៗ ?

ត្រៀមខ្លួនជួយអ្នកជិតខាងដែលខ្វះខាត ?

រៀបចំផែនការធ្វើការប្រជុំប្រកបគ្នាពិសេស ដែលមានការលេងល្បែងកំសាន្ត និង ធ្វើដំណើរកំសាន្ត ដើម្បីអោយសមាជិកកាន់តែមានសេចក្តីស្រឡាញ់ និង ទុកចិត្តគ្នាទៅវិញទៅមក ?

រៀបចំលើកដង្វាយពិសេស ក្នុងករណីដែលមានគ្រោះអាសន្ន ឬ មហន្តរាយនៅក្នុងប្រទេស ?

ជួយអ្នកក្រអោយអាចរៀនជំនាញខាងមុខរបរមួយ អភិវឌ្ឍកសិកម្ម របស់គេ ជាំសួនបន្លែ ថែទាំសុខភាពរបស់គេ ។ល។ ?

បង្រៀនមនុស្សចាស់អោយចេះអាន និង ចេះសរសេរ ?

កិច្ចការបំរើផ្សេងៗ ? ។

ព្រះអំណោយទានខាងថ្លែងព្រះបន្ទូល (ទទួល និង ប្រកាសអំពីព្រះបន្ទូលដែលព្រះជាម្ចាស់ដាក់ក្នុងចិត្ត) ។

១ កូរិនថូស ១២:១០, ២៨, ១ កូរិនថូស ១៤:២៤-៣៣, អេភេសូ ៤:១១-១៤, រ៉ូម ១២:៦, លូកា ៧:២៦-២៧, កិច្ចការ ១១:២៧-២៨, កិច្ចការ ១៣:១-៣, កិច្ចការ ១៥:៣២, កិច្ចការ ២១:៨-១១ ។

តើអ្នកណាអាចថ្លែងព្រះបន្ទូល ដែលព្រះជាម្ចាស់ដាក់ក្នុងចិត្ត ពេលជួបជុំគ្នានៅក្នុងក្រុមជំនុំ ?

ថ្លែងប្រាប់មនុស្សឯទៀតពីព្រះបន្ទូលដែលព្រះជាម្ចាស់ដាក់ក្នុងចិត្ត ក្រៅពីពេលថ្វាយបង្គំក្នុងព្រះវិហារ (ក្នុងសប្ដាហ៍) ?

បកស្រាយព្រះហឫទ័យព្រះជាម្ចាស់ប្រាប់ពួកអ្នកមិនទាន់ជឿ ?

ជួយក្រុមជំនុំអោយអាចយល់ពីភារៈកិច្ចរបស់ខ្លួន ចំពោះក្រុមជំនុំឯទៀត សហគមន៍ និង រដ្ឋាភិបាល ? ។

© Project WorldReach © SEAN